

# ព្រះយេស៊ូវបានចែកចាយដំណឹងល្អ

មនុស្សឃ្លានពេលរូបកាយរបស់ពួកគេត្រូវការអាហារ ។ ពួកគេឃ្លានតាមរបៀបមួយផ្សេងទៀត ពេលពួកគេត្រូវការព្ពពីដំណឹងល្អ ។

ថ្ងៃមួយ មានមនុស្សរាប់ពាន់នាក់បានមកជួបព្រះយេស៊ូវ ។ ព្រះយេស៊ូវបានប្រទានចំណីដល់ពួកគេទាំងអស់គ្នាជាមួយនឹងនំប៉័ងប្រាំដុំ និងត្រីពីរបីប៉ុណ្ណោះ ។

នៅថ្ងៃបន្ទាប់ ពួកគេបានមកជួបព្រះយេស៊ូវម្ដងទៀត ។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកគេឲ្យរកមើលនំប៉័ងមួយប្រភេទផ្សេងទៀត ។ ទ្រង់បានមានបន្ទូលថា « ខ្ញុំជានំប៉័ងជីវិត » ។ ប្រសិនបើប្រជាជនស្វែងរកទ្រង់ និងដំណឹងល្អរបស់ទ្រង់ នោះវិញ្ញាណរបស់ពួកគេនឹងមិនដែលឃ្លានទៀតទេ ។

**អ្នកអាចអានអំពីរឿងនេះនៅក្នុង យ៉ូហាន ៦:៥–១៣, ២២–៣៥ ។**



គ្រាមួយខ្ញុំបានប្រាប់មិត្តរបស់ខ្ញុំថា « ខ្ញុំទៅព្រះវិហារ ហើយរៀនអំពីព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ » ។ ក្រោយមកនាងបានចាប់ផ្ដើមមកព្រះវិហារជាមួយយើង ។ នាងបាននិយាយថា នាងចង់ទទួលបុណ្យជ្រមុជទឹកឆាប់ៗ ! វាធ្វើឲ្យខ្ញុំសប្បាយក្នុងចិត្ត ។

**ម៉ារី អ៊ី អាយុ ៨ ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.**

**តើអ្នកកំពុងតែព្យាយាមក្លាយដូចព្រះយេស៊ូវដោយការជួយអ្នកដទៃដោយរបៀបណា ? សូមសរសេរហើយប្រាប់យើង ! សូមមើលក្របខាងក្រោយដើម្បីដឹងពីរបៀប ។**

## ខ្ញុំអាចជួយមនុស្សដទៃទៀតឲ្យរៀនអំពីព្រះយេស៊ូវគ្រីស្ទ

- តើអ្នកអាចជួយនរណាខ្លះឲ្យរៀនអំពីព្រះយេស៊ូវ ?
- សូមអធិស្ឋាន និងធ្វើផែនការមួយដើម្បីជួយនរណាម្នាក់ឲ្យរៀនអំពីព្រះយេស៊ូវ ។



- អនុវត្តតាមផែនការរបស់អ្នក !

**កាត់ប័ណ្ណនេះចេញដើម្បីរំឭកអ្នកឲ្យបន្តការជួយដូចជាព្រះយេស៊ូវ ។**

រចនារូបភាពដោយ ភីធើរ ហ្វ្រានស៊ីស